# ធម្មទេសនារបស់លោកអភិបាល អូលីវីយេ
# អភិបូជាប្រសិទ្ធីពរលើប្រេងពិសិដ្ឋ
# ភ្នំពេញថ្មី ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩
# ឲ្យយើងទៅជាខ្មើយរបស់ព្រះយេស៊ូ

**អត្ថបទទី១៖ អេសាយ ៦១,១-៩**

សាសន៍ដទៃនឹងនាំគ្នាមក ហើយឃ្វាលហ្វូងចៀមរបស់អ្នករាល់គ្នា កូនចៅរបស់គេនឹងភ្ជួររាស់ដី ហើយដាំទំពាំងបាយជូរឲ្យអ្នករាល់គ្នា។ អស ៦១,៥

**អត្ថបទទី២៖ វិវរណៈ ១,៥-៨**

ព្រះយេស៊ូគ្រីស្តប្រណីសន្តោស ព្រមទាំងប្រទានសេចក្តីសុខសាន្តដល់បងប្អូនដែរ! ព្រះយេស៊ូជាបន្ទាល់ដ៏ស្មោះត្រង់ ព្រះអង្គមានព្រះជន្មរស់ឡើងវិញមុនគេបង្អស់ ហើយព្រះអង្គជាអធិបតីលើស្តេចទាំងអស់នៅផែនដី។ វវ ១,៥

**ដំណឹងល្អ៖ លូកា ៤,១៦-២១**

ព្រះវិញ្ញាណរបស់ព្រះអម្ចាស់សណ្ឋិតលើខ្ញុំ ព្រះអង្គបានចាក់ប្រេងអភិសេកខ្ញុំ ឲ្យនាំដំណឹងល្អទៅប្រាប់ជនក្រីក្រ។ ព្រះអង្គបានចាត់ខ្ញុំឲ្យមកប្រកាសប្រាប់ជនជាប់ជាឈ្លើយថា គេនឹងមានសេរីភាព ហើយប្រាប់មនុស្សខ្វាក់ថាគេនឹងមើលឃើញវិញ។ ព្រះអង្គបានចាត់ខ្ញុំឲ្យមករំដោះអស់អ្នកដែលត្រូវគេសង្កត់សង្កិន។ លក ៤,១៨

បងប្អូនជាទីស្រឡាញ់!

ថ្ងៃនេះ ជាព្រះពរលើប្រេងពិសិដ្ឋទី១០ ដែលខ្ញុំបានថ្វាយអភិបូជាជាមួយបងប្អូនទាំងអស់ក្រោយពេលខ្ញុំជាលោកអភិបាល។ ថ្ងៃនេះ ខ្ញុំចង់ចែករំលែកគំនិតខ្លះៗ ដែលយើងបានរិះគិតជាមួយបូជាចារ្យ ដោយនឹកឃើញដល់ខែតុលាខាងមុខសម្តេចប៉ាបបានសុំឲ្យយើងទាំងអស់គ្នាប្រកាសដំណឹងល្អតាមរបៀបពិសេស។ ប្រកាសដំណឹងល្អ ដោយសារយើងបានទទួលពិធីជ្រមុជទឹក និងព្រះជាម្ចាស់ចាត់ឲ្យយើងទៅប្រកាសដំណឹងល្អ។ នៅពេលដែលព្រះសហគមន៍សកលប្រកាសអំពីខែតុលាខាងមុខនេះ ជាខែពិសេសសម្រាប់ព្រះសហគមន៍មួយចំនួននៅទ្វីបអ៊ឺរ៉ុបដែលជួនកាលភ្លេចតួនាទីរបស់យើងជាអ្នកប្រកាសដំណឹងល្អ និងសព្វថ្ងៃខិតខំដើម្បីឲ្យរចនាសម្ពន្ធរបស់ពួកគេអាចទៅមុខ មិនណែនាំឲ្យមនុស្សថ្មីៗភ្ញាក់ស្មារតីអំពីជីវិតដែលព្រះយេស៊ូប្រទានឲ្យនិងជាពិសេសការសង្គ្រោះ។ ខ្ញុំបាននឹកឃើញដល់ព្រះសហគមន៍ចំនួនដែលមានគ្រីស្តបរិស័ទច្រើនណាស់ ដូច្នេះគេនៅតែចាំឲ្យឪពុកម្តាយដែលជាគ្រីស្តបរិស័ទមានកូនច្រើន ក្រោយមកគេធ្វើពិធីជ្រមុជទឹកច្រើនដែរ នឹងនៅពេលគេផ្ញើរបាយការណ៍ទៅរ៉ូមអំពីចំនួនគ្រីស្តបរិស័ទរីកចម្រើន ព្រះសហគមន៍នេះភ្លេចចេញពីព្រះវិហារ ចេញពីរបងព្រះសហគមន៍ដើម្បីទៅប្រកាសដំណឹងល្អ ដោយសារគេខិតខំរស់នៅដោយថែរក្សាគ្នាឯង។

សម្រាប់ព្រះសហគមន៍របស់យើងនៅប្រទេសកម្ពុជា ពេលដែលយើងនិយាយពីខែពិសេស ដើម្បីទៅប្រកាសដំណឹងល្អ ដើម្បីឲ្យយើងភ្ញាក់ស្មារតីអំពីតួនាទីរបស់យើង។ តួនាទីរបស់យើងជាគ្រីស្តបរិស័ទ ជីវិតធម្មតារបស់យើងជាគ្រីស្តបរិស័ទនិងជាបូជាចារ្យ គឺប្រកាសដំណឹងល្អដល់បងប្អូនឯទៀតៗ។ ព្រះសហគមន៍នៅប្រទេសកម្ពុជាយើងអត់មានគ្រីស្តបរិស័ទជាមហាជន យើងមានគ្រួសារគ្រីស្តបរិស័ទតិច យើងមានព្រះសហគមន៍ជួនកាលតូចណាស់ដែលមានគ្រីស្តបរិស័ទពីរឬបីនាក់ដែលចាក់គ្រឹះនៅកណ្តាលវាលស្រែ ពីរបីនាក់ដែលកំពុងនៅក្បែរភ្នំ ពីរបីនាក់ដែលកំពុងនៅកណ្តាលទីក្រុង ប៉ុន្តែយើងជាព្រះសហគមន៍តូចមែនទែន។ យើងបានទទួលពិធីជ្រមុជទឹក និងព្រះជាម្ចាស់បានចាត់ឲ្យយើងទៅ នេះជាជីវិតរបស់យើងគ្រីស្តបរិស័ទ ជាជីវិតរបស់យើងជាបូជាចារ្យ ជាជីវិតរបស់យើងជាបុព្វជិតបុព្វជិតា ជាលោកអភិបាល។ ខ្ញុំជឿថាសម្រាប់យើងអត់មានសាសនទូតពិសេស ប៉ុន្តែយើងមានប្រជារាស្ត្ររបស់ព្រះជាម្ចាស់ដែលថ្ងៃនេះយើងមើលឃើញតំណាងប្រជារាស្ត្ររបស់ព្រះជាម្ចាស់ទាំងមូល ដែលនៅទីនេះជាក្រុមគ្រីស្តទូត។ ជារៀងរាល់ថ្ងៃយើងត្រូវតែយកចិត្តទុកដាក់តាមរបៀបសន្តប៉ូល "**ខ្ញុំខ្មាស់ណាស់ប្រសិនបើខ្ញុំមិនប្រកាសដំណឹងល្អរបស់ព្រះយេស៊ូ**" ប៉ុន្តែកុំឲ្យយើងឈឺចិត្តពេក កុំឲ្យយើងគិតច្រើនពេកខ្ញុំធ្វើយ៉ាងម៉េចដើម្បីប្រកាសដំណឹងល្អនេះ ខ្ញុំធ្វើយ៉ាងម៉េចដើម្បីឲ្យខ្ញុំទៅជាគ្រីស្តទូតដូចសន្តប៉ូល។ នៅក្នុងជីវិតធម្មតាជាប្រចាំរបស់យើង ដែលជាគ្រីស្តបរិស័ទបានទទួលពិធីជ្រមុជទឹក ជាគ្រីស្តទូតដែលព្រះជាម្ចាស់បានចាត់ចែង ឲ្យយើងទៅជាមេនៅក្នុងម្សៅនៃជីវិតរបស់មនុស្សលោក ឲ្យយើងទៅជាអំបិលដែលផ្តល់រសជាតិពិសេសដល់ជីវិត ដែលប៉ុន្មានដងប៉ុន្មានសារបាត់បង់រសជាតិអស់ហើយ ឲ្យយើងទៅជាពន្លឺដើម្បីណែនាំឲ្យទាំងទីក្រុង ទាំងឆ្នេរសមុទ្រ ទាំងជនបទឲ្យយើងទៅជាពន្លឺតូចមួយដែលមានអត្ថន័យពិសេស។

ឆ្នាំនេះ នៅភូមិភាគភ្នំពេញយើងមាន១៥០នាក់ជាង ដែលនឹងទទួលពិធីជ្រមុជទឹក នៅបាត់ដំបង៨០នាក់ជាង នៅកំពង់ចាម៦០នាក់ជាង សរុបទាំងអស់ជិត៣០០នាក់។ តើ៣០០នាក់ដែលនឹងទទួលពិធីជ្រមុជទឹកជាផ្លែដែលចេញពីការងាររបស់បូជាចារ្យ របស់បងប្រុសបងស្រីរបស់អ្នកស្ម័គ្រចិត្ត? នេះជាផ្លែផលពីការងាររបស់ព្រះជាម្ចាស់ផ្ទាល់ ដែលជាម្ចាស់ចំការ ម្ចាស់ការងារ ម្ចាស់ការប្រកាសដំណឹងល្អ និងបន្តជាការងាររបស់យើងទាំងអស់គ្នាដែលជាគ្រីស្តបរិស័ទដែលបានទទួលពិធីជ្រមុជទឹក យើងជាទូតរបស់ព្រះគ្រីស្ត។ ថ្ងៃនេះ ខ្ញុំឃើញមហាជនរបស់ព្រះគ្រីស្តដែលកំពុងអង្គុយ កំពុងស្តាប់ យើងត្រូវតែអរព្រះគុណព្រះជាម្ចាស់សម្រាប់បងប្អូនដែលជាគ្រីស្តបរិស័ទ ដែលយកចិត្តទុកដាក់ប្រកាសដំណឹងល្អ។ បូជាចារ្យដែលជាគ្រូគង្វាលដែលត្រូវតែស្រឡាញ់ យល់ចិត្តរបស់គ្រីស្តបរិស័ទ និងធ្វើដំណើរជាមួយទាំងអស់គ្នា មិនជ្រើស

រើសអ្នកនេះអ្នកនោះ។ ដោយសារទាំងអស់គ្នា ជាអំណោយទានយ៉ាងពិសេសដែលយើងបាន ទទួលពីព្រះជាម្ចាស់ ដោយមានចិត្តអត់ធ្មត់ ដោយមានចិត្តស្រឡាញ់ ដោយមានចិត្តលើកលែងទោស និងដោយមានចិត្តចេះស្តាប់គ្នា យើងធ្វើយ៉ាងម៉េចដើម្បីយល់ចិត្តគ្នាជាមួយបងប្អូនដែលជាប្រជារាស្ត្ររបស់ព្រះគ្រីស្ត។ យើងត្រូវការដកចេញពីដួងចិត្តរបស់យើង ការវិនិច្ឆ័យទុកជាមុន ផាត់ពណ៌ទុកជាមុន ការអន់ចិត្ត ដើម្បីទៅជាគ្រូគង្វាលដ៏សប្បុរស តាមរបៀបព្រះហឫទ័យមេត្តាករុណារបស់ព្រះជាម្ចាស់និងមិនមែនតាមចិត្តយើង។

ខ្ញុំសូមចែករំលែកអ្វីដែលសំខាន់ ដើម្បីកសាងព្រះសហគមន៍របស់យើង ដែលជាសញ្ញាសម្គាល់នៃព្រះរាជ្យរបស់ព្រះជាម្ចាស់ ខ្ញុំមាន១០ចំណុចដូចខាងក្រោម៖

**ចំណុចទី១៖ យកចិត្តទុកដាក់ថែរក្សាជីវិតខាងផ្លូវវិញ្ញាណ** យើងបានកើតពីព្រះជាម្ចាស់ ព្រះជាម្ចាស់បានណែនាំឲ្យយើងចូលក្នុងលោកិយនេះ វាជាមូលដ្ឋានគ្រឹះនៃអ្វីៗទាំងអស់ ថែរក្សាជីវិតខាងផ្លូវវិញ្ញាណនៅក្នុងទំនាក់ទំនងជាមួយព្រះជាម្ចាស់ នៅក្នុងការអធិដ្ឋានដូចព្រះយេស៊ូដើម្បីបង្កើតទំនាក់ទំនង ដោយសារយើងនៅក្នុងលោកិយនេះប៉ុន្តែយើងមកពីព្រះជាម្ចាស់។

**ចំណុចទី២៖ ឲ្យយើងការពារថែរក្សាអង្គតែមួយ** ថ្ងៃនេះយើងឃើញហើយយើងជួបបងប្អូនមកពីប្រទេសច្រើន សញ្ជាតិច្រើន យើងជាមនុស្សខុសគ្នា ប៉ុន្តែយើងធ្វើយ៉ាងម៉េចទៅជាអង្គតែមួយ។ យើងត្រូវការនឹកឃើញរហូត ព្រះបិតា ព្រះបិតា និងព្រះវិញ្ញាណដ៏វិសុទ្ធ ដែលជាអង្គតែមួយ ឲ្យយើងចេះស្រឡាញ់ទៅជាផ្លូងតែមួយនៅក្នុងព្រះសហគមន៍របស់យើង ជាតួនាទីលោកអភិបាល លោកឪពុក និងយើងជាគ្រីស្តបរិស័ទត្រូវតែយកចិត្តទុកដាក់យល់ចិត្តគ្នាដើម្បីទៅជាគ្រួសារតែមួយ។

**ចំណុចទី៣៖ បរិយាបន្ន** យើងធ្វើយ៉ាងដើម្បីឲ្យមនុស្សយើងចូលគ្នានៅក្នុងគ្រួសារតែមួយ ឲ្យបងប្អូនទាំងអស់មានអារម្មណ៍ថាព្រះសហគមន៍ជាផ្ទះរបស់ខ្ញុំ ព្រះសហគមន៍ជាកន្លែងរបស់ខ្ញុំ ឥតមានមនុស្សដែលអាចចូលបាន និងអត់មានមនុស្សដែលមិនអាចចូលបានទេ។ សក្ខីភាពរបស់លោក មាយ ស៊ិន ដែលនិយាយអំពីសហគ្រិនសង្គម និងភូមិសុខសាន្ត នេះជាកន្លែងមួយដែលយើងខិតខំចូលគ្នាដើម្បីស្រឡាញ់គ្នាទៅវិញទៅមក យើងអត់មើលយើងមកពីណាយើងជាអ្នកណា ប៉ុន្តែយើងដឹងថាយើងទាំងអស់គ្នាយើងមានសមត្ថភាពមួយពិសេសដែលយើងបាន ទទួលពីព្រះជាម្ចាស់ និងយើងអាចស្រឡាញ់គ្នាទៅវិញទៅមក។

**ចំណុចទី៤៖ លើកលែងទោស** យើងជាប្តីប្រពន្ធលើកលែងទោសឲ្យគ្នា យើងជាឪពុកម្តាយលើកលែងទោសឲ្យកូន យើងជាបូជាចារ្យលើកលែងទោសឲ្យគ្នាទៅវិញទៅមក ដើម្បីយើងបន្ត

ធ្វើដំណើរជាមួយគ្នានេះជាកាដូពិសេស ដែលយើងបានទទួលពីព្រះជាម្ចាស់តាមរយៈការលើកលែងទោស។

**ចំណុចទី៥៖ ឲ្យយើងមានបេះដូងមួយ** ដែលចេះស្តាប់ ដែលចេះស្រឡាញ់នៅក្នុងសេចក្តីពិត។ ប្រសិនបើ បេះដូងរបស់យើងចង្អៀតចង្អល់យើងមើលមិនឃើញ យើងស្តាប់មិនឮ ប្រសិនបើបេះដូងរបស់យើងមិនអើពើ យើងគិតតែជីវិតរបស់យើង សុខាមាភាពរបស់យើង។ យើងធ្វើយ៉ាងណា ដើម្បីឲ្យបេះដូងរបស់យើងចេះស្តាប់ ចេះមើល និងចេះស្រឡាញ់យ៉ាងសកម្មនៅក្នុងសេចក្តីពិត ដើម្បីឲ្យមនុស្សទាំងអស់មានជីវិតដ៏បរិបូរណ៍។

**ចំណុចទី៦៖ សន្ទនា** សម័យរបស់យើងមិនជាសម័យសន្ទនា ដោយសារយើងគិតថាយើងមានទំនាក់ទំនងច្រើនណាស់ យើងប្រើបណ្តាញផ្សព្វផ្សាយសង្គមច្រើនដើម្បីទំនាក់ទំនាក់ទំនង។ ប៉ុន្តែប៉ុន្មានដងប៉ុន្មានសារយើងប្រើបណ្តាញផ្សព្វផ្សាយសង្គមទាំងនោះ ដោយលាក់មុខ លាក់ខ្លួន ដោយសារយើងមិនហ៊ានជួបផ្ទាល់ដើម្បីនិយាយពិត ដើម្បីយើងស្តាប់យល់គ្នា ដោយសារពេលយើងផ្ញើសារឲ្យគ្នាមិនដូចយើងមើលភ្នែកទល់មុខគ្នា យើងអាចសម្រុះសម្រួលបញ្ហាជាច្រើននៅក្នុងរបៀបជាគ្រីស្តបរិស័ទ។ ការសន្ទនាជាមួយសាសនាដទៃ ការសន្ទនាជាមួយអាជ្ញាធរមូលដ្ឋាន ការសន្ទនានៅក្នុងសង្គមរបស់យើង សន្ទនាដើម្បីបង្កើតទំនាក់ទំនងជាក់ស្តែង។

**ចំណុចទី៧៖ ឲ្យយើងយកចិត្តទុកដាក់រស់នៅក្នុងសង្គមបច្ចុប្បន្ននេះ** មិនមែននៅក្នុងសង្គមដែលយើងសុបិន មិនមែននៅក្នុងសង្គមដែលយើងចង់បាន ប៉ុន្តែសង្គមដែលយើងមានថ្ងៃនេះ នៅភូមិខ្ញុំជីវិតយ៉ាងម៉េច នៅខណ្ឌខ្ញុំជីវិតយ៉ាងម៉េច នៅសង្កាត់ខ្ញុំជីវិតយ៉ាងម៉េច នៅទីក្រុងខ្ញុំជីវិតយ៉ាងម៉េច។ ព្រះយេស៊ូបានរើសធម្មសាលា ព្រះយេស៊ូបានរើសឆ្នេរសមុទ្រ ព្រះយេស៊ូបានរើសភូមិមួយ ព្រះយេស៊ូបានរើសផ្ទះមួយ ដើម្បីទៅ ដើម្បីមើល ដើម្បីណែនាំឲ្យគេមានជីវិតតទៅទៀត។

**ចំណុចទី៨៖ ឲ្យយើងធ្វើយ៉ាងម៉េចដើម្បីបន្តអប់រំ** អប់រំមនុស្សទាំងស្រុងណែនាំឲ្យមនុស្សអាចទទួលអ្វីៗទាំងអស់ ដើម្បីធ្វើជាមនុស្សយ៉ាងពេញលក្ខណៈនៅក្នុងសង្គមបច្ចុប្បន្ននេះ និងជាពិសេសដើម្បីឲ្យមនុស្សយើងទៅជាមនុស្សសុចរិតដែលមានចិត្តស្មោះត្រង់។ យើងមិនខ្វះគំរូមនុស្សសុចរិតទេ យ៉ូហានបាទីស្ត សន្តយ៉ូសែប ព្រះនាងម៉ារី និងជាពិសេសព្រះយេស៊ូដែលជាមនុស្សសុចរិតយ៉ាងពិតប្រាកដ មិនគ្រាន់តែទទួលរងទុក្ខលំបាកប៉ុន្តែណែនាំឲ្យយើងចូលនៅក្នុងជីវិត។

**ចំណុចទី៩៖ ឲ្យយើងមានចិត្តដូចឪពុកម្តាយ** ព្រះសហគមន៍ជាគ្រួសារមួយ ព្រះសហគមន៍ជាដើមឈើមួយយ៉ាងធំបំផុត ដែលមានបេះដូងមួយដ៏ធំធេងដែលចេះទទួលស្វាគមន៍គ្រប់បក្សាបក្សីដែលចង់បង្កើតសំបុកមួយ។

**ចំណុចទី១០៖ ឲ្យយើងមានចិត្តច្នៃប្រឌិត** ដោយសារដំណឹងល្អថ្មីរាល់ពេលព្រឹក កុំឲ្យយើងគិតថាដំណឹងល្អយើងធ្លាប់ស្តាប់ ទេសនាដដែលៗ ថ្ងៃនេះមានព្រះបន្ទូលមានអត្ថន័យថ្មី។ **ឲ្យយើងធ្វើយ៉ាងម៉េចដើម្បីឲ្យភ្ញាក់ជារៀងរាល់ថ្ងៃ** ដើម្បីមើលឃើញស្នាព្រះហស្តរបស់ព្រះជាម្ចាស់នៅក្នុងសញ្ញាដ៏តូចតាចនៃជីវិត។ **ឲ្យយើងធ្វើយ៉ាងម៉េចដើម្បីយកចិត្តទុកដាក់ទទួលខុសត្រូវអស់ពីសមត្ថភាព** ឲ្យមានការតស៊ូផង ឲ្យមានចិត្តអត់ធ្មត់ផង។ ម្សិលមិញ ថ្ងៃនេះ ថ្ងៃស្អែក ព្រះសហគមន៍អាយុជាង២០០០ឆ្នាំហើយ ប៉ុន្តែព្រះសគមន៍មានឫសដើម្បីឲ្យយើងរស់នៅថ្ងៃនេះរៀបចំអនាគត។ **ឲ្យយើងទៅជាអ្នកបម្រើ** យើងបានបម្រើអស់ពីសមត្ថភាព ប្រសិនបើដល់ពេលវេលាយើងឈប់សម្រាក់យើងសម្រាក់ ដោយដឹងថាមានគ្រីស្តបរិស័ទ មានបូជាចារ្យ មានបងប្អូន ដែលបន្តដើម្បីបម្រើនិងប្រកាសដំណឹងល្អ ដើម្បីណែនាំឲ្យសេចក្តីសុខរបស់ព្រះជាម្ចាស់យាងមកលើផែនដីនេះ។ ព្រះសហគមន៍បាននៅ ព្រះសហគមន៍កំពង់នៅ ព្រះសហគមន៍នឹងនៅតទៅទៀត ដូច្នេះរួមជាមួយសន្តិតេរេសានៃក្រុងលីស្សឺ ឲ្យយើងយកចិត្តទុកដាក់រស់នៅថ្ងៃនេះសម្រាប់ព្រះជាម្ចាស់ដើម្បីឲ្យមានផ្កាយ៉ាងច្រើនដុះឡើងនៅលើផែនដីរបស់យើង លើទឹក លើសមុទ្រ ដើម្បីឲ្យយើងឃើញស្នាព្រះហស្តរបស់ព្រះអង្គ ដែលណែនាំឲ្យយើងពោរពេញដោយសេចក្តីសុខ។

កុំឲ្យយើងខ្លាចធ្វើជាខ្នើយរបស់ព្រះយេស៊ូ នៅក្នុងរោងព្រះយេស៊ូប្រសូតខ្ញុំបានឃើញព្រះយេស៊ូដែលកំពុងសម្រាក់ ប៉ុន្តែប៉ុន្មានដងប៉ុន្មានសារព្រះយេស៊ូបានភ្ញាក់ពីដេក ដោយសារព្រះអង្គអត់មានខ្នើយ។ ហេតុនេះហើយ ឲ្យយើងទៅជាខ្នើយដែលព្រះយេស៊ូទន្ទឹងរង់ចាំ និងខ្នើយនេះជាបេះដូង ដួងចិត្តរបស់យើង ពោរពេញដោយសេចក្តីស្រឡាញ់។ ឲ្យយើងទៅជាខ្នើយដ៏តូចដើម្បីណែនាំឲ្យព្រះយេស៊ូសម្រាកយ៉ាងស្រួល និងណែនាំឲ្យព្រះបន្ទូលដែលយើងស្តាប់ថ្ងៃនេះទៅជារូបរាងលើទឹកដីប្រទេសកម្ពុជាយើង។ អាម៉ែន៕